*រាជធានីភ្នំពេញ ; ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៤*

# សេចក្តីសំរេចលេខ ១១៧ សសរ.

# ស្តីពីការ បង្កើតគណៈកម្មការត្រួតពិនិត្យការបាត់បង់សំភារៈនៅនាយកដ្ឋានសំភារៈនៃក្រសួងសាធារណៈការ និង ដឹកជញ្ជូន

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ័ន្ម ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសាធារណៈការ និង ដឹកជញ្ជូន ។

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះត្រួតពិនិត្យការបាត់បង់សំភារៈនៅនាយកដ្ឋានសំភារៈនៃក្រសួងសាធារណៈការនិងដឹកជញ្ជូន ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬតំណាង | ប្រធាន |
| ២- តំណាងរាជរដ្ឋាភិបាល (លេខាធិការដ្ឋានអធិការកិច្ច) | អនុប្រធាន |
| ៣- តំណាងក្រសួងសាធារណៈការ និង ដឹកជញ្ជូន | សមាជិក |
| ៤- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- តំណាងធនាគារជាតិកម្ពុជា | សមាជិក |

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ច :

- ត្រួតពិនិត្យសំភារៈ នៅនាយកដ្ឋានសំភារៈ នៃ ក្រសួងសាធារណៈការ និង ដឹកជញ្ជូន ។
- ធ្វើរបាយការណ៍ ស្តីពីសំភារៈដែលបាត់បង់មូលហេតុ នៃការបាត់បង់ និង សំភារៈដែលនៅសេសសល់ និងលើកវិធានការការពារ ថែរក្សាសំភារៈ ដែលនៅសេសសល់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

ប្រការ ៣ : សមាជិក គណៈកម្មការ ត្រូវអញ្ជើញចូលរួមប្រជុំ និង អនុវត្តការងារ តាមការណែនាំរបស់ប្រធាន ។ គណៈកម្មការ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីដំណើរការងាររបស់ខ្លួន ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួង សាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ដែលមានការពាក់ព័ន្ធ និង ឯកឧត្តមអស់លោក ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តី សំរេចនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *